**BBI0070**

### សម្ភាសន៍ជាមួយឈ្មោះ កង សាត ភេទប្រុស អាយុ៥៤

### មានស្រុកកំណើតនៅភូមិចំបក់ធំ ឃុំពន្ធសាំង ស្រុកអង្គស្នួល ខេត្តកណ្ដាល

### សព្វថ្ងៃរស់នៅភូមិស្វាយជ្រុំ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង

### សម្ភាសន៍ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១១

### មុខងារសម័យខ្មែរក្រហមៈ ការពារព្រំដែន

### មុខងារបច្ចុប្បន្នៈ កសិករ

### សម្ភាសន៍ដោយៈ សុខ វណ្ណៈ

### សរុបទំព័រៈ ២៥

វណ្ណៈ៖ ខ្ញុំឈ្មោះសុខ វណ្ណៈ មកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមកដល់ស្រុកកំរៀងស្រុកពូផ្ទាល់ព្រោះចង់ដឹងប្រវត្តិរឿងរ៉ាវបងប្អូនដែលធ្លាប់តស៊ូបែកចេញពីឪពុកម្ដាយបងប្អូន ហើយការសម្ភាសន៍របស់ខ្ញុំហ្នឹងព្រោះចង់ឲ្យក្មេងជំនាន់ក្រោយបានដឹងបានឮថាប្រទេសយើង ស្រុកយើងមានបញ្ហាអីខ្លះនៅក្នុងសម័យខ្មែរក្រហមឬក្រោយសម័យខ្មែរក្រហម ឬក៏មុនសម័យហ្នឹងទៀតណាពូ អញ្ចឹងកាលដែលខ្ញុំសម្ភាសន៍ជាមួយពូហ្នឹងតើពូអនុញ្ញាតិឲ្យខ្ញុំសម្ភាសន៍យកទៅចងក្រងទុកជាសៀវភៅឲ្យក្មេងបានដឹងបានឮទេពូ អញ្ចឹងខ្ញុំសូមឲ្យពូនិយាយឮបន្តិចដើម្បីឲ្យស្រួលស្ដាប់ ។ អញ្ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ តើពូឈ្មោះអី?

សាតៈ ខ្ញុំឈ្មោះកង សាត ។

វណ្ណៈ៖ សព្វថ្ងៃពូអាយុប៉ុន្មានហើយ?

សាតៈ អាយុ៥៤ឆ្នាំ ។

វណ្ណៈ៖ ប្រពន្ធពូឈ្មោះអីដែរ?

សាតៈ ឈ្មោះម៉ន នឿន ។

វណ្ណៈ៖ គាត់អាយុប៉ុន្មានហើយ?

សាតៈ គាត់អាយុ៤៥ឆ្នាំ ។

វណ្ណៈ៖ សព្វថ្ងៃពូមានកូនប៉ុន្មាននាក់?

សាតៈ មានកូន៤នាក់ ។

វណ្ណៈ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មានពូ?

សាតៈ  ស្រី៣  ប្រុស៤ ។

វណ្ណៈ  កូនពូរាល់ថ្ងៃនៅក្នុងបន្ទុកឬក៏បានចេញធ្វើការខ្លះហើយ?

សាតៈ  នៅក្នុងបន្ទុក ។

វណ្ណៈ  សព្វថ្ងៃនៅក្នុងបន្ទុកទេ?

សាតៈ  បាទ!

វណ្ណៈ  ហើយសព្វថ្ងៃពូប្រកបមុខរបរអីដែរ?

សាតៈ  សព្វថ្ងៃប្រកបមុខរបរធ្វើចំការ ។

វណ្ណៈ  ចុះពូស្រុកកំណើតដែលពូកើតនៅណា?

សាតៈ  នៅភូមិចំបក់ធំ ។

វណ្ណៈ  ឃុំ?

សាតៈ  ឃុំពន្ធសាំង ។

វណ្ណៈ  ស្រុក?

សាតៈ  អន្លង់ស្នួល  ខេត្តកណ្តាល ។

វណ្ណៈ  ចុះសព្វថ្ងៃពូនៅណាដែរ?

សាតៈ  សព្វថ្ងៃនៅភូមិស្វាយជ្រុង ។

វណ្ណៈ  ភូមិស្វាយជ្រុង?

សាតៈ  ស្រុកកំរៀង ។

វណ្ណៈ  ឃុំអីដែរ?

សាតៈ  ឃុំអូរដា ។

វណ្ណៈ  ខេត្តបាត់ដំបង?

សាតៈ  បាទ!

វណ្ណៈ  កាលដែលពូនៅស្រុកកំណើតពូរៀនបានថ្នាក់ទីប៉ុន្មាន?

សាតៈ  រៀនបានថ្នាក់ទី១២ចាស់ ។

វណ្ណៈ  ហើយមើលអក្សរបានទេ?

សាតៈ  មើលអក្សរបាន  តែបើមើលលេខមិនបានទេ ។

វណ្ណៈ  អានបាន?

សាតៈ  បាន ។

វណ្ណៈ ចុះឪពុកពូឈ្មោះអីដែរ?

សាគៈ ឈ្មោះកង សន ។

វណ្ណៈ ចុះម្ដាយ?

សាគៈ ម្ដាយឈ្មោះប៊ុន សៅ ។

វណ្ណៈ គាត់សព្វថ្ងៃនៅរស់ឬក៏ស្លាប់អស់ហើយ?

សាគៈ នៅរស់ទាំងអស់ តែគាត់អាយុច្រើនហើយ ។

វណ្ណៈ គាត់រស់នៅស្រុកកំណើត?

សាគៈ បាទ! គាត់រស់នៅស្រុកកំណើត ។

វណ្ណៈ ចុះពូមានបងប្អូនបង្កើតប៉ុន្មាននាក់?

សាគៈ ខ្ញុំមានបងប្អូនបង្កើត៦នាក់ ។

វណ្ណៈ ៦នាក់ហ្នឹងនៅទាំងអស់?

សាគៈ នៅទាំងអស់ ។

វណ្ណៈ កាលចូលចលនាតស៊ូ ពូចូលតែម្នាក់ឯងឬក៏មានបងប្អូនចូលដែរ?

សាគៈ ចូលតែម្នាក់ឯងទេ ក្នុងភូមិវាច្រើនតែមានគ្រួសារខ្ញុំចូលតែមួយទេ ។

វណ្ណៈ គ្រួសារពូចូលតែមួយហ្នឹងទេ?

សាគៈ បាទ! ក្រោយមកទៀតឆ្នាំ១៩៧៣ រដ្ឋអំណាចភូមិ ឧទាហរណ៍ថាយើងមិនទៅក៏ត្រូវតែធ្វើកាលជំនាន់ខ្ញុំស្ម័គ្រចិត្តតែម្ដង ហើយកាលជំនាន់៧០ដោយសម្ដេចលោកប្រកាសថាលោកកូនអើយចូលព្រៃម៉ាគីរំដោះសម្ដេចឡើងមកកាន់អំណាចឡើងវិញ ។

វណ្ណៈ ហើយម៉េចទៀតពូ ពូនិយាយទៅតែម្ដងទៅ ។

សាគៈ ហើយក្រោយមកទៀតមានរដ្ឋអំណាចដែលគេហៅថាខ្មែរក្រហមណា៎ កាន់កាប់អំណាចដោយវ៉ៃឈ្នះមានព្រាបជាងស្រុក ចង់កាន់កាប់អំណាចហ្នឹងគឺថាមិនអាចចូលចរចារក្នុងអំឡុងឆ្នាំ១៩៧៣ទេ ។

វណ្ណៈ បាទ!

សាគៈ ដល់ពេលអញ្ចឹងចង់ចូលកាន់កាប់រដ្ឋអំណាច ដោយមើលឃើញតែខ្លួនឯងឈ្នះមិនចូលចរចារទេ ដូចថាមានព្រាបជាងខាងលន់ នល់ ។

វណ្ណៈ បាទ!

សាគៈ ហើយបន្តមកទៀតឆ្នាំ១៩៧៣ ៧៤មកទល់គ្នាឆ្នាំ៧៥ឈ្មះ កងរបស់ខ្ញុំរដ្ឋគេដោះស្រាយឲ្យទៅនៅរតនៈគិរីដើម្បីការពារជាមួយបងប្អូនវៀតណាម ដោយមានកងពល៨០១ ។

វណ្ណៈ ឆ្នាំប៉ុន្មាន?

សាគៈ ឆ្នាំ១៩៧៦ ។

វណ្ណៈ ៧៦ទៅនៅរតនៈគិរី?

សាគៈ បាទ!

វណ្ណៈ ការពារព្រំដែន?

សាគៈ ហ្នឹងអើយ ។

វណ្ណៈ អញ្ចឹងខ្ញុំចង់សួរ៧០ ៧១ ៧២ ចលនាវីជាមួយទាហានលន់ នល់ហ្នឹង តើពូឃើញថាមានការខូចខាតយ៉ាងម៉េចដែរ?

សាគៈ ខូចខាតលោកប្អូន ទីមួយអារឿងសង្គ្រាមវិនាសកម្មខាងលោកលន់ នល់តែខាងព្រៃទេ ព្រៃវាខូចតិចមែនតែនៅតែបាត់បង់ ប៉ះពាល់អាយុជីវិតគ្រប់គ្នាទាំងអស់ នៅលើស្មារតីប្រយុទ្ធ តែមួយលុយ មួយទៀតដោយស័គ្រចិត្ត ខ្លាំងត្រង់ថាស័គ្រចិត្ត ។

វណ្ណៈ ទាហានមួយប្រើលុយ?

សាគៈ បាទ! ទាហានមួយប្រើលុយ ហើយទាហានមួយទៀតអប់រំស្មារតីប្រយុទ្ធ ស្រលាញ់ទឹកដីដោយយល់ទៅតាមចក្រព័ទ្ធអាមេរិចចូលលុកនោះ មើលឃើញនៅកំហឹងបុគ្គល កំហឹងវណ្ណៈជិះជាន់វណ្ណៈ ដល់ពេលអញ្ចឹងគេបំពាក់ហើយណាលោកប្អូន ។

វណ្ណៈ បាទ!

សាគៈ បំពាក់នៅរឿងវណ្ណៈជាតិ វណ្ណៈកសិករ បំបិទពន្ធដារ តែរឿងសុំវិភាគទានតែមួយដដែលហ្នឹងខ្ញុំពិនិត្យទាំងអស់ការរស់នៅសព្វថ្ងៃនេះ មួយម៉ាដំបរ ហើយមួយទៀត៤ ៤វាមានពាក្យច្រើនហើយម៉ាដំបរវាតិច តែបើប្រៀបធៀបវាស្មើរហ្នឹងគ្នា ។

វណ្ណៈ ចុះការដែលតស៊ូ កាលដែលខ្មែរក្រហម៧២,៧៣ហ្នឹង ខាងកម្លាំងខ្មែរក្រហមមានទៅពឹងខាងវៀតណាមទេកាលហ្នឹង?

សាគៈ អត់មានទេលោកប្អូន ។

វណ្ណៈ ចុះខាងលន់ នល់អាចទៅពឹងខាងធៀវគី?

សាគៈ បាទ! ក្រោយមកសម្តេចបានយកតាម៉ុកធ្វើកូនអុក តាម៉ុកយកសម្តេចធ្វើកូនអុកនោះដឹងទាំងអស់លោកប្អូន ។

វណ្ណៈ៖ ឆ្នាំណាដែលតាម៉ុកយកសម្តេចធ្វើកូនអុក?

សាតៈ ឆ្នាំ១៩៧០វៃក្នាបណ្តើរមានធៀវគឺមកចូលណាំ មានអាធៀវ អាធ្មេញខ្មៅនោះ ដល់ពេលវាចេញមកអញ្ចឹងវាជួយដកទ័ពចេញពីប្រទេសកម្ពុជាយើងទៅព្រំដែនវិញ ។

វណ្ណៈ៖ ពូនិយាយបន្តទៀតមកពូ?

សាតៈ ដល់ពេលអញ្ចឹងអាមួយវាមានខ្មែរសមួយចំនួន ហើយទ័ពមានរបួសសម្លាប់គ្នាឯងរហូតប្រវត្តិសាស្រ្តសកម្មភាពនេះ អាមួយហៅខ្មែរសសម្លាប់គ្នាឯងដោយស្របច្បាប់ អាមួយវាមានខ្សែផ្សេងៗពីគ្នា ។

វណ្ណៈ៖ អញ្ចឹងចលនាទាំងអស់ហ្នឹងបានធ្វើឲ្យប្រជាជនក៏រងគ្រោះ ហើយទ័ពក៏រងគ្រោះដែរ?

សាតៈ បាទ! ត្រឹមត្រូវហើយ ព្រោះសង្រ្គាមវិនាសកម្ម សង្រ្គាមមិនជឿនលឿន សង្រ្គាមមិនរីកចម្រើនដល់ជាតិនឹងប្រជាជនយើងទេ ។

វណ្ណៈ៖ អញ្ចឹងកាលពូចូលបដិវត្តិដោយសារពូឃើញថាកំបាំងវណ្ណៈ,

សាតៈ ចង់បានសម្តេចលោកគ្រប់គ្រងប្រទេសជាតិវិញ ព្រោះស្តេចត្រឹមត្រូវ ហើយជំនាន់យើងសម្តេចលោកដឹកនាំប្រជាជន ឧទាហរណ៍មួយ ពេលដែលលោកយាងទៅកន្លែងណាគឺមេឃស្រទុំរហូត យើងមានជំនឿជឿជាក់លើស្តេច គោរពបូជា ។

វណ្ណៈ៖ អញ្ចឹងពូមានជំនឿបានពូចូល?

សាតៈ បាទ!

វណ្ណៈ៖ ចុះដល់ពេលក្រោយរំដោះឆ្នាំ១៩៧៥ខ្មែរក្រហមកាន់កាប់ទាំងមូលហ្នុងតើពូមានបានវៃចូលទីក្រុងភ្នំពេញដែរឬក៏អត់ទេ?

សាតៈ បានចូលក្រុងភ្នំពេញដោយឃើញជាក់ស្តែងដូចតទៅ ទីមួយរំដោះសុំឲ្យប្រជាជននៅទីក្រុងហ្នឹងជម្លៀសតែ៣ថ្ងៃទេ ឲ្យគាត់ចេញ៣ថ្ងៃហើយឲ្យគាត់មកវិញ ដល់ពេលអញ្ចឹងប៉ុល ពតមានឲ្យចូលណាលោកប្អូន មិនថាតែទ័ពខ្លួនឯង មិនថាតែម៉ែឪខ្លួនឯង នឹងប្រជាពលរដ្ឋទេគឺដាច់ខាតមិនឲ្យចូល សូម្បីតែខ្លួនឯងក៏មានទោសដែរ យើងកាលនោះគេដាក់ច្បាប់ផ្តាច់ការ មិនមានសិទ្ធអីទាំងអស់សូម្បីតែខ្ញុំក៏ត្រូវតែស៊ីបបរដែរ ដូច្នេះយើងមើលឃើញថាការមិនឲ្យខ្មែរវិលត្រលប់គ្មានសិទ្ធសេរីភាព តែការដឹកនាំមួយវាមិនល្អត្រង់ថាធ្វើដើម្បីអ្នកណា ខ្ញុំមិនយល់ទេលោកប្អូនអញ្ចឹងបានថាអ្នកដឹកនាំធំតាំងពីព្រះករុណាធំ ហើយវាគ្មានអីគួឲ្យជឿជាក់លើខ្លួនឯងផង វាអត់មានអីត្រូវទំនប់បំរុងខ្លួនឯងថាបានអ៊ីនិងមកគ្រប់គ្រងណាំ ធ្វើទៅវាមានតែន័យ តែវាអត់មានខ្លឹមសារ ។

វណ្ណៈ  កាលពូចូលទៅឆ្នាំ៧២,៧៣ហ្នឹងមានកងពលមានអីនូវ?

សាតៈ  មានហើយ ។

វណ្ណៈ  ពូនៅកងពលណា?

សាតៈ  ខ្ញុំនៅកងពលលេខ១៨ ។

វណ្ណៈ  កងពលលេខ១៨ពីណាគេគ្រប់គ្រង?

សាតៈ  បងរឿន ។

វណ្ណៈ  រឿន?

សាតៈ  បាទ! ខ្ញុំអត់ស្គាល់នាមត្រកូលទេ ស្គាល់តែឈ្មោះ ។

វណ្ណៈ  ប្រធានកងពល?

សាតៈ  ប្រធានកងពល ។

វណ្ណៈ  តាសារឿន០៥ហ្នឹងមែន?

សាតៈ  បាទ! ហ្នឹងអើយ ហើយបើវរៈសេនាធំស្គាល់អស់ហ្នុង ។

វណ្ណៈ  មានពីណាគេខ្លះ?

សាតៈ  ទីមួយមាន ម៉ូតតែអត់ស្គាល់នាមត្រកូលទេ តាសុន តាគី ។

វណ្ណៈ  ចុះក្រោយមកទៀត បន្ទាប់មកទៀតដូចថាដល់ឆ្នាំ៧៥ចូលដល់ទីក្រុងភ្នំពេញហើយ កងពលមានការប្រែប្រួលទៀតទេ?

សាតៈ  ប្រែប្រួលហ្នឹងគឺ៨០១ ៨០១ហ្នឹងមានតែតា០៥គាត់នៅគ្រប់គ្រងដដែល ។

វណ្ណៈ  ៨០១វិញ?

សាតៈ  ៨០១ហ្នឹងរំលាយកងពលអស់មកចំរុះកងពលធំហ្នុង ។

វណ្ណៈ  ចុះ៧៥រំលាយកងពល?

សាតៈ  បាទ!

វណ្ណៈ  ចូល៨០១?

សាតៈ  ចូលកងពល៨០១ ។

វណ្ណៈ  តាសារឿនដែរ?

សាតៈ  តាសារឿន ។

វណ្ណៈ  តាសារឿន០៥ហ្នឹងគាត់កាន់ខាងភូមិភាគណា?

សាតៈ  ខ្ញុំភ្លេចហើយខាងភូមិភាគហ្នឹង ។

វណ្ណៈ ខាងមណ្ឌលគិរីមែន?

សាតៈ ខាងរតនៈគិរី ។

វណ្ណៈ អញ្ចឹងគាត់កាន់រហូត,

សាតៈ កាន់រហូតមកទាល់ចូលព្រៃ រុករានរហូតមកទាល់គេសម្លាប់គាត់ ដូចថាគេហៅខ្មែរក្រហមតែគេសម្លាប់គ្នាឯង ដែលគេហៅយកបុណ្យស័ក្តនោះណ៎ ដូចថាសម្តេចនាយករដ្ឋមន្ត្រីជាអ្នកចាញ់អញ្ចឹងណាលោកប្អូន ហើយអាចនិយាយបានទៀតថា ពេលដែលសម្លាប់គាត់ប៉ុល ពតចង់សម្លាប់ឲ្យអស់អ្នកតស៊ូគ្នាឯងហ្នឹង ដល់ពេលអញ្ចឹងតាម៉ុកគាត់ខឹងដែរណ៎ គាត់ក៏សម្រេចចិត្តថាឲ្យកំទេចចោលបងប្អូនហ្នឹងកុំឲ្យនៅ ព្រោះតាម៉ុកគាត់ចូលជាមួយរាជរដ្ឋាភិបាលដែរហ្នឹង គាត់មានគំនិតមួយសម្រុះសម្រួលតែប៉ុល ពតគាត់ជម្រុះចោលអត់ចូលទេ គាត់សុខចិត្តស្លាប់ ដល់ពេលអញ្ចឹងគេរំលាយគាត់ចោលតែម្តងទៅ មិនមែនគេរំលាយទេ តាម៉ុកគាត់សម្រេចរំលាយ ។

វណ្ណៈ ចុះតាសុន សានស្លាប់ឆ្នាំណា?

សាតៈ ឈប់សិនខ្ញុំគិតកុំឲ្យខុសពេលវេលា សម័យពួកខ្ញុំនេះខ្ញុំចូលរាជរដ្ឋាភិបាលមិនដឹងឆ្នាំប៉ុន្មានដែរទេលោកប្អូន ។

វណ្ណៈ ចុះឥលូវពូមានដឹងថាស្លាប់មុនតាសុន សេនឬក៏ក្រោយ?

សាតៈ ស្លាប់ដំណាលគ្នាលោកប្អូន ឆ្នាំតែមួយហ្នឹងហ្នុងគ្រាន់តែមុនក្រោយទេ ស្លាប់ដំណាលគ្នាមុនក្រោយថ្ងៃទេអត់ដល់ខែទេ ។

វណ្ណៈ អញ្ចឹងពូ ពូបានចូលក្រុងភ្នំពេញ ខ្ញុំចង់និយាយថាចូលក្រុងភ្នំពេញរយៈពេលប៉ុន្មានបានគេបញ្ជូនពូទៅរតនៈគិរី?

សាតៈ បានរយៈពេល៣ខែ ។

វណ្ណៈ នៅភ្នំពេញឆ្នាំ១៩៧៥បាន៣ខែ?

សាតៈ បាន៣ខែទៅធ្វើប្រឡាយនៅខត្តុង ជីកប្រឡាយនៅខត្តុងបានមួយហើយធ្វើស្រែនឹងប្រយ៉ាបពួកខ្ញុំហ្នឹងហើយជាអ្នកធ្វើស្រែប្រយ៉ាប អូសដោយខ្លួនឯងនឹងនង្គ័ល នាំគ្នាអូសនឹងកម្លាំងកងទ័ពហ្នឹង ។

វណ្ណៈ អញ្ចឹងកងទ័ពក្រោយមកធ្វើស្រែ?

សាតៈ បាទ! ធ្វើស្រែពិតប្រាកដណាស់លោកប្អូនព្រោះខ្ញុំជាអ្នកអញ្ចឹងហើយ ។

វណ្ណៈ អញ្ចឹងនៅឆ្នាំ៧៥ដដែលពូនៅ?

សាតៈ បាទ! ៧៥ដដែលហ្នឹង ។

វណ្ណៈ ៧៥ពូទៅព្រំដែនវិញទៀត?

សាតៈ ខែ១ ថ្ងៃ១ទៅរតនៈគិរីណា ។

វណ្ណៈ អញ្ចឹងមិនមែន៧៥ទេ ៧៦បានទៅ?

សាតៈ ៧៦បានទៅលោកប្អូន ឆ្នាំ៧៦ ខែ១ ថ្ងៃ១ដែលចុះទៅ ។

វណ្ណៈ ពូទៅនៅព្រំដែនរតនៈគិរីហ្នឹងតើយោធាហូបចុកមិនមានបញ្ហាអីទេ?

សាតៈ លំបាកមែនទែន ។

វណ្ណៈ លំបាក?

សាតៈ លំបាកហ្នឹងមិនមែនលំបាកល្អមៗទេ គឺលំបាកខ្លាំងតែម្តង ទៅវ៉ៃហ្នឹងគឺស៊ីតែដំឡូងលាយជាមួយផ្លែចេកនឹងពោតដែលយើងដាំបានណាលោកប្អូន កិនលាយចូលគ្នា ។

វណ្ណៈ អញ្ចឹងកាលនៅការពារព្រំដែនហ្នឹងការពារកុំឲ្យខ្មែររត់ចេញទៅខាងក្រៅឬក៏ការពារយ៉ាងម៉េច?

សាតៈ ការពារហ្នឹងទីមួយគឺការពារមិនឲ្យបងប្អូនវៀតណាមឆ្លងកាត់ ទីពីរគេហៅកងពលលោកចក្រីនោះលោកអុកឡុងនៅមណ្ឌលគិរីហ្នឹង គាត់ទៅមួយចំហៀងហើយ ហើយចេះតែមានជួលជាមួយបងប្អូនវៀតណាមហើយណា៎ តែពួកខ្ញុំអត់មានទេ អត់មានទំនាក់ទំនងជាដាច់ខាត ដកកងពលទប់ទល់ជាមួយបងប្អូនវៀតណាម កងពល១០ទល់ហ្នឹង១០ កាលជំនាន់នោះបើដឹងថាបងប្អូនវៀតណាមចូលមករំដោះអញ្ចឹងលំបាកអី បើខំនោះគឺខំដើម្បីជាតិ ហើយប្រជាជនខ្លួនឯង ម៉ែឪខ្លួនឯង អញ្ចឹងដូចថាមិនដឹងអ្នកណាល្អអ្នកណាអាក្រក់នោះទេ ហើយមកដល់សព្វថ្ងៃនេះឃើញថាលោកនាយករដ្ឋមន្រ្តីលោកឈ្លាសវៃណា ធ្វើឲ្យយើងខ្ញុំមានស៊ីមានចុក មានការដឹងច្បាប់ទម្លាប់អាហ្នឹងក្រៅរដ្ឋាភិបាលអប់រំមកណាលោកប្អូន មានបងប្អូនក្នុងស្រុកក៏មាន បងប្អូនក្រៅស្រុកក៏មាន ក្រៅប្រទេសក៏មាន មានការដឹកនាំដឹងច្បាស់ ហើយមានស៊ីមានចុក មានផ្លូវដើរ នេះដោយឃើញថាការឈ្លាសវៃរបស់អ្នកដឹកនាំមួយៗ តែក្រោយមកវាមានចន្លៀតបន្តិចដូចថាពេលយើងរស់នៅនេះណា៎ ដីរបបចែកដីងថាប្លង់មួយៗដូចថាលោកក្មួយចែកឲ្យខ្ញុំអញ្ចឹងដឹងទាំងអស់គ្នា ហើយដីមានតែ៧,៨វ៉ៃហ្នឹង វ៉ៃដែលធ្វើនៅនោះនេះគេកាប់យកបាត់ តែអត់ទាន់ដោះស្រាយបានទេ ព្រោះវាមានទំនាស់ ។

វណ្ណៈ អញ្ចឹងអាហ្នឹងចាំខ្ញុំសួរវគ្គក្រោយទៀត ។

សាតៈ បាទ!

វណ្ណៈ ហើយខ្ញុំចង់សួរថាអំឡុងពេលដែលនៅរតនៈគិរីហ្នឹង ពូនៅតាំងពី៧៦រហូតដល់រត់យួន៧៩តែម្តងមែនទេឬក៏មានការផ្លាស់ប្តូរទៅណាទៀត?

សាតៈ អញ្ចេះលោកប្អូនជាមួយបងប្អូនវៀតណាម មណ្ឌលគិរីគេបាក់ហើយណា៎ ។

វណ្ណៈ បាទ!

សាតៈ ដល់ពេលបាក់អញ្ចឹងបងប្អូននៅរតនៈគិរីនៅតាមភ្នំរហូតហ្នឹង ការលំបាករបស់បងប្អូនអត់មានស៊ីស៊ីគឺជីកក្តួចជីកអីស៊ីហ្នឹង ទាល់តែវៃគ្នាជាមួយបងប្អូនវៀតណាមរហូតទាល់ឡើងភ្នំឆ្នាំ៨៧ឡើងមកដល់ភ្នំ ឡើងមកដល់ភ្នំដងរែកណាតាមជួរភ្នំជាមួយលាវជាមួយអី ថាភ្នំ១១០០អត់មានស៊ីស៊ីទេ មានតែផ្លៃឃ្លោក ហើយមានដំឡូងបារាំងហើយដំឡូងជ្រូក ខ្ញុំសម្គាល់នេះគឺមិនមានចង់មានបំណងអីគេគឺទៅតាមសណ្តានចិត្តខ្លួនឯងដែលធ្វើកន្លងមក ធ្លាប់ជួបប្រទះហើយតែវាអត់មានន័យ អត់មានន័យហ្នឹងអត់មានយ៉ាងម៉េច ខ្ញុំចង់បញ្ជាក់ប្រាប់ប្អូនថាធ្វើវាអត់បានប្រយោជន៍ រីឯអ្នកក្រោយមានស័ក្តយស ប្រជាជនគេយកវៃចោល ។

វណ្ណៈ ប្រជាជនយ៉ាងម៉េចបានគេយកវៃចោល?

សាតៈ គេបោកគ្រាប់បែក ហើយពួកគាត់អត់មានបានដេកទេមួយយប់ទល់ភ្លឺ ។

វណ្ណៈ ពូនិយាយហ្នឹងកាលជំនាន់ណា?

សាតៈ ជំនាន់កាលឆ្នាំ៧៣ ។

វណ្ណៈ ជំនាន់ហ្នឹងគេទម្លាក់គ្រាប់បែក ។

សាតៈ ទម្លាក់គ្រាប់បែកអញ្ចឹងហើយបានខ្ញុំព្រួចលនាណាលោកប្អូន ដល់អញ្ចឹងវាសរុប យើងយល់អញ្ចឹងវាល្អត្រឹមត្រូវហើយ អ្នកសម្គាល់នេះល្អមែនទេ ខ្ញុំនិយាយអត់មានវគ្គចេះតែប៉ាតណាប៉ាតណី ក្នុងឆ្នាំនោះដែលខ្ញុំយកមកនិយាយនេះប្រជាជនគាត់ខឹងណា៎ ដល់ពេលអញ្ចឹងសូម្បីតែមាន់មួយក៏គាត់ឲ្យដែរជូននឹងមនុស្សណា៎ ជួនកាលគាត់ឲ្យមាន់ប្រាំ ព្រោះកាលំបាកលោកប្អូនអើយអត់មានបានដេក វាវេទនាណាស់ដូចឆ្លុះកង្កែបអញ្ចឹង វាអាសេមអាសាម ដាក់ទ្រុងអញ្ចឹងទៅឃើញបាញ់ ខ្ញុំនិយាយឲ្យត្រង់ចុះដូចកូនមាន់អញ្ចឹងដេញយកតែម្តងជំនាន់ហ្នឹង ចុះស្រុកខ្ញុំនៅខាងត្បូងខត្តុងណាលោកប្អូន ហើយជំនាន់នោះខ្ញុំអត់និយាយលាក់បាំងអីទេ ខ្ញុំវាធ្លាប់ជួបការលំបាក ហើយការស្រួលហ្នឹងវាតិចជាង ។

វណ្ណៈ អញ្ចឹងកាលពូនៅរតនៈគិរីហ្នឹងពូចេញទៅឆ្នាំ៧៦ ហើយពូមានដឹងថាខ្មែរក្រហមសម្លាប់ថ្នាក់កម្មាភិបាលដែរ សម្លាប់ប្រជាជនដែរ?

សាគៈ ដំបូងខ្ញុំអត់ទាន់បានយល់ទេ តែឥឡូវខ្ញុំបានយល់ខ្លះ ដឹងថាសមាជិកប្រធានក្រុមមួយ ប្រធានក្រុមកងទ័ពណាក៏មានសិទ្ធធ្វើបាបមហាជនក្នុងកងដែរ វាក្រឡេមក្រឡុមតែពីនាក់គ្នាវាហ្នឹងវរៈសេនាធំវរៈសេនាតូច ដល់ពេលអញ្ចឹងទៅវាមានការបាត់បង់ ហើយប៉ុល ពតបើដឹងអញ្ចឹងក៏វាមិនធ្វើស្រែ ការយល់ដឹងរបស់គាត់ក៏គាត់ចង់បានល្អ តែឧទាហរណ៍ថាសមាជិកក្នុងក្រុមបក្ស ៨១០របស់ខ្ញុំគាត់ឲ្យហូបមានរបបក្នុងមួយអាទិត្យមាន៣ដង ដល់ពេលអញ្ចឹងអត់គ្រប់របបរបស់គាត់ទេ ដល់ពេលអញ្ចឹងវរៈសេនាធំមានមុខរាយការណ៍តែរឿងហូបគ្រាន់ តែក្នុងអង្គភាពហូបអត់គ្រាន់ទេលោកប្អូន ដល់ពេលអញ្ចឹងវាប៉ះពាល់ទៅលើអ្នលដឹកនាំ ។

វណ្ណៈ ចុះពូគិតថាកាលជំនាន់៣ឆ្នាំដែលដឹកនាំហើយធ្វើឲ្យប្រជាជនវេទនាដោយសារអត់អាហារ ប្រជាជនធ្វើការអត់មានពេលសម្រាក ហើយមានការកាប់សម្លាប់ហ្នឹងពូគិតថាជាកំហុសរបស់ថ្នាក់លើឬជាកំហុសរបស់ថ្នាក់ក្រោម បើតាមពូយល់?

សាគៈ ខ្ញុំវិនិច្ឆ័យដោយស្មោះត្រង់ចុះ មិនកាន់ជើងខាងលើឬខាងក្រោមទេ ឧទាហរណ៍ថាខាងក្រោមរាយការណ៍ថាល្អតែខាងក្រោមហ្នឹងអត់ដឹងទេលោកប្អូន ពីព្រោះនៅខាងលើដូចលោកប្អូនអញ្ចឹងបើខ្ញុំនេះមូលមតិថាឥឡូវ ក្នុងកងរបស់ខ្ញុំ ឧទាហរណ៍ថាក្នុងប្រជាជនក្នុងសាខាគេណា៎ ថាសាខាខ្ញុំទទួលមួយគរអញ្ចឹង ហូបគ្រប់គ្រាន់ មានស្បៀកពាក់ អត់មានដឹងណាដឹងតែថាល្អ ដល់ពេលអញ្ចឹងគាត់អត់មានបានពិនិត្យមើលក្រោមទេ អាងតែថាដូចយើងរាល់ថ្ងៃនេះអញ្ចឹងណាលោកប្អូន អ្នកនៅតែរួចឲ្យឆៅដុតឲ្យខ្លោចដូចរាល់ថ្ងៃ ឃើញទេគ្រាន់តែគាត់ខំកែមែនទែន កែមហាកែតែនៅតែមិនបានណា ខ្ញុំឃើញជាក់ស្តែងនៅបច្ចុប្បន្ននេះមិនមែននិយាយឲ្យវែងឆ្ងាយអីទេ យើងមើលឃើញទាំងអស់គ្នា សូម្បីតែលុយយោធិនហ្នឹងក៏គាត់ខំណាស់ គាត់មិនឲ្យមានកើតឡើងខ្លាំង ដកសិទ្ធពីនេះទៅនោះនៅតែមាន អានេះមើលឃើញជាក់ស្តែងអញ្ចឹងណាលោកប្អូន ។

វណ្ណៈ បាទ!

សាគៈ មិនបន្ទោសអ្នកណាបានទេ ព្រោះអ្នកដឹកនាំមិនចង់ឲ្យមានគ្រោះថ្នាក់ទេ ។

វណ្ណៈ ការពារកាលហ្នឹងមានយួនវ៉ៃដែរ?

សាគៈ វ៉ៃរហូតលោកប្អូន នៅព្រំដែនខ្ញុំដឹងទាំងអស់ នៅព្រំដែនណាៗមកត្រឹមណា តែឥឡូវយើងមានបងប្អូនដែលស័គ្រចិត្ត គេអត់សូវមានអារម្មណ៍ទៅខាងហ្នឹងមិនអាចនិយាយបានទេ ដូចមាត់ហើយនឹងធ្មេញអញ្ចឹងណា៎ មានតែប្រាសាទព្រះវិហារទេដែលនាំឲ្យយើងចិត្តក្តៅគគុក ។

វណ្ណៈ ចុះជំនាន់ហ្នឹងពូមានដឹងថាប្រជាជនអត់បាយ ហើយស្លាប់ពិតមែនទេ?

សាតៈ មាន ដឹង តែគ្រាន់តែក្នុងនោះយើងធ្វើអត់បាន សូម្បីតែខ្លួនឯងអត់មានបានទៅជួបម្ដាយទេ ពី១៩៧០រហូតទៅរតនៈគិរីហ្នឹងអត់មានបានទាក់ទងម្ដាយសោះ ។

វណ្ណៈ អញ្ចឹងពូអត់មានសុំច្បាប់ទៅលេងម្ដាយទេ?

សាតៈ សុំអត់បានទេលោកប្អូន វាថាអត់ឲ្យមកទេចាំមានផ្លូវថ្នល់ ចាំមានរថភ្លើងធ្វើសិន ខ្ញុំអត់ឃាត់ទេបងប្អូន តែគ្រាន់តែក្នុងកងហ្នឹងគេប្រជុំដកពិសោធន៍ស៊ីជម្រៅការខ្វះខាត អ្នកអត់ចេះអក្សរក៏ឲ្យធ្វើដែរឲ្យតែចំនេញក្នុងការដឹកនាំ ក្នុងមួយថ្ងៃទៅមួយថ្ងៃឲ្យតែរីកចំរើន ។

វណ្ណៈ ចុះពូដូចថាកាលដែលពូធ្វើហ្នឹង កាលសម័យហ្នឹងហើយអត់បានមកលេងផ្ទះអញ្ចឹង តើពូមានអារម្មណ៍យ៉ាងម៉េច?

សាតៈ នឹកអ្នកមានគុណហ្នឹងដូចថាវាហួសពីសណ្ដានចិត្ត តែខំធ្វើយ៉ាងម៉េចដើម្បីខ្លួនកុំឲ្យគេចាប់គេចងណា៎ ។

វណ្ណៈ បាទ!

សាតៈ ទោះបីគេដកសិទ្ធពីវរៈសេនាធំមកនៅជាមហាជនធម្មតាក៏អត់មានតូចចិត្តដែរ ព្រោះយើងធ្វើដោយស្មោះកុំឲ្យមាន ជំនាន់នោះឲ្យតែដកចិត្តអត់សកម្មភាពអត់ប្រយុទ្ធហើយត្បូងចបសែនរីងហើយ ។

វណ្ណៈ និយាយអញ្ចឹងកងវរៈនៅក្នុងកងរបស់ពូហ្នឹង កងពលពូមានគ្នាប៉ុន្មាននាក់?

សាតៈ មួយកងពលខ្ញុំពេញសិទ្ធវាច្រើនពាន់ណាស់លោកប្អូន លោកប្អូនគិតអញ្ចេះមួយវរៈសេនាធំមាន ៣៣០នាក់ មួយវរៈសេនាតូចណា៎ បើអនុសេនធំមាន១៣០នាក់ មួយអនុសេនាធំ ។

វណ្ណៈ អញ្ចឹងម៉ាវរៈសេនាធំមាន៣០០ ។

សាតៈ មួយវរៈសេនាធំមាន៣០០ ហើយមួយវរៈសេនាធំមាន១០០ជាងទេ ។

វណ្ណៈ អញ្ចឹងមានវរៈសេនាធំទេ?

សាតៈ មាន ។

វណ្ណៈ មានវរៈសេនាធំ មានវរៈសេនាតូច?

សាតៈ បាទ! មួយវរៈសេនាធំមានបីវរៈសេនាតូច ។

វណ្ណៈ អញ្ចឹងមាន៣គ?

សាតៈ បាទ! ក្នុងមួយអនុសេនាធំមានអនុសេនាធំ៤នាក់ ។

វណ្ណៈ បាទ

សាតៈ ហើយអនុសេនាតូចដូចគ្នា ។

វណ្ណៈ អញ្ចឹងមួយកងពលមានប៉ុន្មានវរៈ?

សាតៈ មួយកងពលមានច្រើនវរៈណាស់លោកប្អូន។

វណ្ណៈ មានច្រើន?

សាតៈ មានច្រើនណាស់ តែខ្ញុំដឹងតែវរៈសេនាធំខ្ញុំវាមាន៣វរៈសេនា។

វណ្ណៈ អញ្ចឹងមួយកងពល៨០១ហ្នឹងដឹកនាំតែតាសារឿន០៥ទេ?

សាតៈ មានតែតាសារឿន០៥ទេ។

វណ្ណៈ ហើយមានពីណាទៀតទេ?

សាតៈ មានកែវ សារឿន ក្នុងកងពលហ្នឹងណា៎។

វណ្ណៈ កែវ សារឿនដែរ?

សាតៈ បាទ!

វណ្ណៈ កែវ សារឿនហ្នឹងគេសម្លាប់គាត់ដែរឬក៏អត់ទេ?

សាតៈ សម្លាប់។

វណ្ណៈ ក្រោយ៧៩?

សាតៈ បាទ!

វណ្ណៈ គាត់ជំនួយការតាសុន សាន?

សាតៈ ជំនួយការតាសុន តាសុននៅកោះកុង។

វណ្ណៈ តាសុនហ្នឹងគាត់កាន់កងពល?

សាតៈ កងពលជាមួយអ្នកទាំង៣ហ្នឹងមានបីរូប តែមួយរូបទៀតខ្ញុំភ្លេចហើយ ទាំងអស់មាន៤នាក់។

វណ្ណៈ បាទ! អញ្ចឹងកងពល៨០១ហ្នឹងដែរ?

សាតៈ ហ្នឹងអើយ។

វណ្ណៈ ប៉ុន្តែអ្នកទាំងអស់ហ្នឹងសព្វថ្ងៃនៅរស់ឬក៏ស្លាប់?

សាតៈ ស្លាប់អស់ហើយ។

វណ្ណៈ ស្លាប់ក្រោយ៧៩?

សាតៈ បាទ! តាកែវ សារឿនគាត់មានទោសតាំងពីមុនពេលដែលគាត់ទៅនៅ៨០១នោះ ព្រោះកាល
ហ្នឹងគេដកមក កាលហ្នឹងឲ្យតែដកបាត់ខ្លួនៗហើយ មិនដឹងជាមូលហេតុអីទេ។

វណ្ណៈ ចុះពូនៅពេលមុន១៩៧៩នេះ ពេលយួនចូលស្រុកហេតុអីបានជាពូអត់ទៅរកស្រុកកំណើត?

សាគៈ អាហ្នឹងគេហៅចលនាដែលយើងវ៉ៃកងពលវៀតណាមខ្លាំង អត់ហ៊ានចូលស្រុកទេខ្លាចបងប្អូនវៀតណាមធ្វើបាប ដល់ពេលអញ្ចឹងកំហឹងចេះតែមានហើយ ដល់ពេលអញ្ចឹងដាច់ខាតទោះបីឃើញប្អូនខ្ជួនឯងក៏ត្រូវតែដាក់ដែរ មិនបាច់ចាំដល់អ្នកដទៃទេឲ្យតែមកទោះបីប្អូនខ្លួនឯងក៏លៃដែរ ឪខ្ជួនឯងក៏លៃដែរ ។

វណ្ណៈ លៃម៉េច?

សាគៈ បាញ់ចោល ហេតុអីបានជាគេបាញ់ចោលព្រោះដណ្តើមដីគ្នានៅ បើទុកឪ ឪមកហើយទល់គ្នាទាល់តែឃើញមុខកូនមុខឪហ្នឹងបាន បើថាគ្រាន់តែក្រឡេកឃើញឪគេបាញ់ងាប់ មានកន្លែងណាជ្រកទៀតដាច់ខាតត្រូវតែធ្វើណាលោកប្អូន ចង់ក៏ធ្វើមិនចង់ក៏ធ្វើដើម្បីរស់ បើវ៉ៃទៅមានអីស៊ីខ្លះដូចថាគេមកពីស្រុកមកគេមានអង្ករ គេមានប៊ីចេងហើយនឹងអំបិល ហើយខ្ញុំអត់មានអំបិលទេតាំងពី៧៩រហូតមកដល់៨៧ ៨៧ឡើងភ្នំណាលោកប្អូនបានមានអំបិលមានប៊ីចេងហូប ។

វណ្ណៈ ចុះពី៧៩ដល់៨៧ហ្នឹងយើងវ៉ៃជាមួយទាហានរដ្ឋាភិបាលខាងក្នុងជាមួយវៀតណាម?

សាគៈ បាទ!

វណ្ណៈ ដល់ពេលវៀតណាមមកពូមានដឹងនៅឆ្នាំណាទេ?

សាគៈ ភ្លេចហើយលោកប្អូនអើយ ។

វណ្ណៈ ឆ្នាំ៨៧វៀតណាមដកចេញទៅ?

សាគៈ បាទ!

វណ្ណៈ អញ្ចឹងនៅសល់ខ្មែរហើយនឹងខ្មែរទេ?

សាគៈ បាទ?

វណ្ណៈ ខ្ញុំចង់សួរថាពេលដែលវ៉ៃជាមួយវៀតណាម ជាមួយខ្មែរក្រហមអីហ្នឹង ហើយមានប៉ារ៉ាវ៉ៃចូលគ្នាតើកាលហ្នឹងវ៉ៃគ្នាខ្លាំងឬក៏ក្រោយមកខ្មែរវ៉ៃខ្មែរខ្លាំងដែរ?

សាគៈ វ៉ៃគ្នាខ្លាំងហ្នឹង គ្រាន់តែបងប្អូនប៉ារ៉ាគាត់ផ្សេងពីពួកខ្ញុំ ថ្ងៃដែលទៅជួបមុខគ្នាខ្ញុំទៅ ហើយផែនការតែធ្វើអីមួយគឺដឹងមុនហើយទាហានខ្មែរវ៉ៃ ព្រោះយើងមានព្រាបខាងវ៉ៃជាមួយបងប្អូនខ្មែរ គាត់ដូចថាមិនមានមនុស្សទុកចិត្តនឹងគ្នា វ៉ៃរត់ចោល ហើយពួកនោះតែវ៉ៃដេញ ដល់ពេលអញ្ចឹងអត់មានធ្វើអីបែកទេ ពួកខ្មែរក្រហមខ្ញុំសូមប្រាប់លោកប្អូនទៅចុះបើថាធ្វើអីមួយទោះបីងាប់ក៏យកមកដែរ ទោះបីរលួយក៏យកកប់វិញ យកមនុស្សដែលទុកចិត្ត ផ្តល់នៅគ្រួសារដែលបាត់បង់ ផ្តល់ឲ្យជំរុំជ្រក ការពារ ហើយសពហ្នឹងគឺថាធ្វើបុណ្យគោរពវិញ្ញាណក្ខន្ធឲ្យ មានតែតា

ខៀវទេដែលបាត់បង់ អ្នកដែលពិការអត់មានឈ្មោះ បើថាអ្នកពិការឲ្យតែដល់ខែដល់បុណ្យត្រូវតែជប់លៀងគាត់លើកទឹកចិត្តគាត់ ទើបតែឥលូវនេះទេអត់សូវមានការទុកចិត្ត ។

វណ្ណៈ ខ្ញុំសូមសួរមួយទៀតដូចថា៧៩ហើយនៅតែតាសារឿនគ្រប់គ្រងពូដដែល?

សាតៈ បាទ!

វណ្ណៈ អត់មានមកតាម៉ុកទេ ចុះដល់ពេលមកដល់ដងរែក?

សាតៈ មកដល់ដងរែកអ៊ឹម៉ុក ។

វណ្ណៈ ហើយតាសារឿនមកនៅក្រោមវិញ ។

សាតៈ នៅក្រោមតាម៉ុក ហើយនៅក្រោមតាប៉ុល ពត ។

វណ្ណៈ អញ្ចឹងខ្ញុំចង់ដឹងរឿងរ៉ាវកាលហ្នឹងថានៅខាងអន្លង់វែងអត់មានប៉ារ៉ាឡូកឡំទេណោះ?

សាតៈ ប៉ារ៉ាគេនៅផ្សេងទេលោកប្អូន ។

វណ្ណៈ គេនៅផ្សេងទេ?

សាតៈ បាទ! គេនៅផ្សេងទេអត់មាននៅច្រឡូកច្រឡំទេ ហ្នឹងត្រូវបានតែពេលនៅជួបគ្នា ដល់ក្រោយមកជួនកាលវ៉ៃគ្នាមួយពូតសិនគេរត់ចេញ ពួកខ្ញុំតាមយកអីមកវិញអញ្ចឹងមក ។

វណ្ណៈ អញ្ចឹងសម្ភារៈដែលកម្លាំងខ្មែរក្រហមទទួលបានដូចជាស្បៀងអាហារ ក៏គ្រាប់កាំភ្លើងមកពីខាងណាជំនួយ?

សាតៈ មកពីចិន ។

វណ្ណៈ ហើយនៅខាងអន្លង់វែងពូនៅហ្នឹងរហូតហ្នង?

សាតៈ នៅរហូត ។

វណ្ណៈ រហូតដល់ឆ្នាំណាបានពូមកនៅនេះ?

សាតៈ ខ្ញុំមកដូចជា៩០ប៉ុន្មានទេ ។

វណ្ណៈ ពូមកនេះមុនសាមារណកម្មមែនទេ?

សាតៈ មុនសាមារណកម្មប្រហែលជា៧ឆ្នាំ ។

វណ្ណៈ អញ្ចឹងប្រហែលជាឆ្នាំ៩០ជាងហើយ?

សាតៈ យើងដាក់ប្រហែលជាប៉ុណ្ណឹងចុះ ព្រោះដាក់ប៉ុណ្ណឹងវាទំនង យើងមកនេះដោយរដ្ឋជាមួយតាខៀវ កាលហ្នឹងតាខៀវហៅមក ហៅពីអន្លង់វែងមក មកជ្រកដីនេះពឹងពាក់លើកងពលលោកសុខ គង់ គាត់ពួកខ្ញុំជ្រកកោនខ្ញុំនឹកគុណគាត់មកដល់សព្វថ្ងៃនេះ ព្រោះពួកខ្ញុំកាលនោះមានតែមានវត្តមួយទេ ហើយដល់ពេលមកនៅនេះមានកន្លែងជ្រកកោនព្រោះបានលោកជួយ ។

វណ្ណៈ គាត់ជាអភិបាល ។

សាគៈ បាទ! គាត់ជាអភិបាលរង ខ្ញុំដឹងគុណគាត់ដោយស្មោះអស់ពីដួងចិត្ត ។

វណ្ណៈ កាលហ្នឹងលោកសុខគង់ហ្នឹងគាត់កាន់អីដែរ?

សាគៈ គាត់កាន់កាលហ្នឹងគាត់កងពល ។

វណ្ណៈ អញ្ចឹងមានតែប្រធានកងពល?

សាគៈ បាទ! ប្រធានកងពល ។

វណ្ណៈ ប្រធានកងពលប៉ុន្មានដែរ?

សាគៈ អារឿងប្រធានកងពលមកដល់សព្វថ្ងៃក៏នៅតែអត់ទាន់យល់ដែរ តែគ្រាន់តែដឹងថាសិទ្ធ ហើយខ្ញុំមកនៅក្នុងអគ្គភាពមន្ទីរ៩២ណា៎ ដល់ពេលអញ្ចឹងការយល់ដឹងពីកងពលអត់ដឹងទេ មួយចង្កោមវាតិចនៅក្នុងខ្លួនឯង ម៉ាជុំវិញហ្នឹងហ្មង ។

វណ្ណៈ អញ្ចឹងតាកន តាសុខ ភាពអីគាត់អត់មានមកខាងនេះទេ?

សាគៈ បាទ! អត់មានមកខាងនេះទេ ។

វណ្ណៈ តាកន តាហុងអីគាត់នៅខាងផ្សេង?

សាគៈ បាទ!

វណ្ណៈ អញ្ចឹងតាសុខ គង់ គាត់នៅនេះ?

សាគៈ ហ្នឹងអើយ ។

វណ្ណៈ គាត់នៅជាមួយតាខៀវ?

សាគៈ នៅក្រោមការគ្រប់គ្រងរបស់តាខៀវដែរ ។

វណ្ណៈ ចុះពូខ្ញុំចង់ដឹងពីនៅអន្លង់វែង ខ្ញុំចង់ដឹងហេតុផលដែលសម្លាប់តា០៥ តាសារឿន និងសម្លាប់តាសុនសេន ពូមានដឹងរឿងរ៉ាវខ្លះទេ?

សាគៈ ខ្ញុំមិនមែនឃើញដោយភ្នែកផ្ទាល់ទេលោកប្អូន ប៉ុន្តែគ្រាន់តែអ្នកនៅក្នុងភូមិកងនៅកងហៅមកណា៎ ដូចថាស្គាល់គ្នាដូចបងប្អូនបង្កើតអញ្ចឹងមកហៅគ្នាសួរមូលហេតុថាចុះកាលដែលសម្លាប់ហ្នឹងបងប្អូនឃើញដែរ ថាពេលដែលសម្លាប់ហ្នឹងពូសួរតែស្នូរកាំភ្លើង ហើយគ្នាអោបតែកូនហើយយកកម្លាំងគេចដែរណា៎លោកប្អូន ដល់ពេលព្រលឹមឡើងឃើញគេដុតពិតប្រាកដហ្មង ទាំងតា០៥អីហ្នឹងឃើញច្បាស់ថាគេដុត ហើយតាមដានជាងមេហើយអ្នកណាមិនចង់សួរនាំលោកប្អូនចង់ដឹងដំណឹងពីគ្នាសុខទុកណាលោកប្អូន រស់ប៉ុន្មាននៅប៉ុន្មាន ការចង់ដឹងចង់យល់ពីគ្នាទៅវិញទៅ

មកណាលោកប្អូន ស្លាប់ពិតប្រាកដហើយលោកប្អូន ប៉ុន្តែគ្រាន់តែមិនដឹងម៉ោងមិនដឹងថ្ងៃណា វាមិនចាំច្បាស់?

វណ្ណៈ អញ្ចឹងពូមានដឹងថាពីណាគេជាអ្នកបញ្ជាឲ្យសម្លាប់គា០៩ហើយនឹងគាសុន សេនទេ?

សាតៈ គាម៉ុកហ្នឹងឯង គាត់មានលំបាកអីកំទេចចោលហ្នឹង សម្លាប់គ្នាគៗ ។

វណ្ណៈ គាម៉ុកបញ្ជាឲ្យសម្លាប់ព្រោះអត់ទុកចិត្តមែនទេ?

សាតៈ អត់ទុកចិត្ត ។

វណ្ណៈ អញ្ចឹងសូម្បីតែខ្មែរក្រហមគ្នាឯងក៏មានបញ្ហាសម្លាប់គ្នាមិនអាចនឹកស្មានដល់ដែរ?

សាតៈ បាទ!

វណ្ណៈ អញ្ចឹងកូនចៅរឹតតែមានការភ័យខ្លាចទៀតហើយអញ្ចឹង?

សាតៈ ដូចខ្ញុំនិយាយជាមួយលោកប្អូនអញ្ចឹងណា៎ វាមិនមានប្រសិទ្ធភាពដូចដែលខ្លួនឯងធ្វើនោះទេ មានដាក់ស្តែងដែលគេហៅថាសញ្ញាប័ត្រមួយ ហើយពីរទៀតមានតែកម្លាំងហើយនឹងប្រាជ្ញា នឹងការអនុវត្ត ដល់ពេលមកកំណត់គុណភាពយើងធ្វើបានមួយថ្ងៃគេថាពីថ្ងៃអញ្ចឹង ហើយដល់ក្រោយមកគេឃើញយើងធ្វើខុសគេដកលេខទុកចិត្តទុកចិត្តភ្លាម យើងធាក់ទងញាតិមិត្តដែលខុស ហើយគឺថាយើងហើយ ទោះដឹកនាំថ្នាក់ណាក៏ដោយក៏គេចាប់កំហុសយើងថាយើងស៊ុមក្រលំគ្នាយើង គេអត់ឲ្យយើងមានកាន់ទ័ពតទៅទៀតទេ គេហៅតានដានតាមខ្សែ ។

វណ្ណៈ ចុះពូដូចថាពី៧៩ដល់សម័យសាមារណេកម្មហ្នឹង ពូកាលហ្នឹងធ្វើទាហានយោធាខ្មែរក្រហមតស៊ូនៅមុខឬក៏នៅក្រោយ?

សាតៈ នៅមុខលោកប្អូន ។

វណ្ណៈ អញ្ចឹងមានប្រាក់ខែដែរទេ?

សាតៈ អត់មានទេ ។

វណ្ណៈ អត់មានទេ?

សាតៈ បាទ! គឺកម្លាំងសុទ្ធ ។

វណ្ណៈ អ៎! កម្លាំងសុទ្ធហ្នឹង?

សាតៈ ហ្នឹងអើយ ។

វណ្ណៈ បានតែរបបហូបទេ?

សាគៈ ហ្នឹងអើយបានតែរបបទេ បានរបបហូបតែឡើងភ្នំរាប់ពាន់ភ្នំដល់ព្រំដែនបងប្អូនវៀតណាម ភ្នំយក្សគ្រាក់ ភ្នំកន្ទុយនាគ ច្បាស់ណាស់លោកប្អូនបើរាប់រៀបព្រំដែនខ្ញុំស្គាល់ច្បាស់ ពីណាទៅណាតាំងពីអូរយក្សដៅទៅទល់គ្នានឹងយក្សគ្រាក់ កន្ទុយនាគ ។

វណ្ណៈ អញ្ចឹងពូដូចថាកាលសម័យតស៊ូវាច្របូលច្របល់គ្នាខ្លាំងណាស់ ធ្វើឲ្យមនុស្សស្លាប់ទាំងសងខាង ហើយហេតុអីបានជាតាខៀវ តាសុន សេនយកពូពីអន្លង់វែងមកនៅនេះវិញ គាត់យល់ឃើញយ៉ាងម៉េច?

សាគៈ ការគ្រប់គ្រងរបស់គាត់នៅក្នុងអង្គភាព៥២គាត់គ្រប់គ្រងពួកឃ្លាំង ឃ្លាំងផ្ទុក ឃ្លាំងចែកចាយឲ្យកងពល ។

វណ្ណៈ បាទ!

សាគៈ ដល់ពេលអញ្ចឹងយកកម្លាំងគាត់មកវិញ កាលមុនគាត់នៅគ្រប់គ្រងនៅច្រកមួយដែរនោះ ដល់ពេលនេះតាសាឡុតសបញ្ជាឲ្យគាត់មកនៅស៊ីសុផុនខាងជើងនេះណាស់ គាត់យកកម្លាំងពួកខ្ញុំមកវិញ ដល់ហើយមកមានទឹកដីខ្លួនឯងណា ដល់ហើយលោកអភិបាលសុខ គង់គាត់អនុគ្រោះយកមកនៅហើយស្គាល់ត្រឹមហ្នឹងហ្នង ។

វណ្ណៈ មកនៅតាមមាត់អូរ?

សាគៈ បាទ!

វណ្ណៈ កម្លាំងច្រើនទេកាលយកមកហ្នឹង?

សាគៈ កម្លាំងយកមកមាន៣អនុសេនាធំ បើអីលន់នោះគាត់ពេទ្យត្រឹមត្រូវហ្នងលោកប្អូន ច្រកពេទ្យគឺគាត់ទទួល មួយច្រកគាត់មួយមានតែគាត់ហ្នឹងហើយដែលព្យាបាលកាត់វះ ។

វណ្ណៈ ចុះនៅកំរៀងកាលហ្នឹង បើដូចនៅម៉ាឡៃគេហៅថាតំបន់១០២គេដាក់ឈ្មោះអញ្ចឹង?

សាគៈ បាទ!

វណ្ណៈ ហើយនៅកំរៀងអញ្ចឹងគេដាក់តំបន់អីដែរ?

សាគៈ អត់យល់ទេលោកប្អូន បើដឹងតែ១០២ ព្រោះធ្លាប់ទៅធ្វើនៅហ្នឹង អាហ្នឹងដឹងថាទៅធ្វើគ្រាប់ទៅធ្វើមីនខ្លួនឯងហ្នឹងហ្នង ។

វណ្ណៈ អញ្ចឹងដល់ពេលពូមកនៅនេះ កកើតដំបូងអត់មានផ្ទះសម្បែងទេ?

សាគៈ មានតែផ្ទះព្រៃឫស្សី ។

វណ្ណៈ ខ្ញុំចង់ដឹងពីដើមមក ពីបុរាណមកមានផ្ទះសម្បែងទេហ្នឹង?

សាត៖ ផ្ទះសម្បែងនៅកំរៀងមាន តែតាមនេះគឺអត់មានទេមានតែដើមស្វាយចាស់ពីដើមដែលចោរលួច វាដូចតែលួចគោលួចអីនៅលាក់ខ្លួនគ្នោតចាស់ៗនោះណា៎ ដល់ពេលអញ្ចឹងទៅស៊ីគ្រាប់ធ្លាក់អាហ្នឹងពិតប្រាកដលោកប្អូន ហើយបើស្រែគេត្រឹមខាងនោះ មានស្រែចាស់មិនដឹងតាំងពីជំនាន់ណាទេ ឃើញដាក់ស្តែង ហើយខ្ញុំលប់អស់ហើយព្រៃៗ

វណ្ណៈ៖ និយាយរួមពីដើមចាស់បុរាណមកគឺមិនមានភូមិរស់នៅទេ មានតែព្រៃសុទ្ធហ្នឹង?

សាត៖ បាទ! មានតែព្រៃសុទ្ធៗ

វណ្ណៈ៖ ដូចថាមានមួយដុំដែរតែនៅកំរៀង?

សាត៖ បាទ!

វណ្ណៈ៖ នៅភូមិចាស់?

សាត៖ ហ្នឹងហើយភូមិចាស់ៗ

វណ្ណៈ៖ ហើយមិនស្រួលមិនមែនខ្មែរយើងសុទ្ធទៀតហ្នឹង?

សាត៖ ជនជាតិក្រឡាជនជាតិអីហ្នឹង ហើយឃើញស្នាមឆ្អឹងស្នាមអំបែងក្អមអីណា៎លោកប្អូន មិនដឹងជាជំនាន់តាៗណាមកទេព្រោះដុះព្រៃប៉ុនៗនេះហើយ ព្រៃមុំទូនដៃក្បែខាងជើងកំរៀងៗ

វណ្ណៈ៖ ចុះដោយសារពូនៅក្រោមតាខៀវ តាសុន សេនដែរខ្ញុំចង់ដឹងថាកាលឆ្នាំ៩០ប៉ុន្មានទេខ្ញុំឮថាដូចមានចង់ប្រមូលដូចថាកម្លាំងវៃលែងចង់ទៅមុខហើយដោយសារប្រជាជនរាំករកស៊ីអញ្ចឹង ដល់ពេលអញ្ចឹងលែងសូវចង់វៃតទល់ហើយ ហើយមានការចង់ប្រមូលរបស់ដាក់រួមមែនអត់?

សាត៖ ត្រឹមត្រូវមែនៗ

វណ្ណៈ៖ មានមែន?

សាត៖ ដកគោរទេះ អ្នកមានគោដកគោ អ្នកមានរទេះដករទេះ អ្នកមានម៉ូតូដកម៉ូតូ អ្នកមានឡានដកឡានៗ

វណ្ណៈ៖ ពីណាគេជាអ្នកបញ្ជាឲ្យដក?

សាត៖ តាខៀវហ្នឹងហើយ ពិតប្រាកដអត់មានប្រកែក ខ្ញុំរស់នៅក្នុងចង្កោមហ្នឹង ពួកខ្ញុំដកពីហ្នឹងមកពួកខ្ញុំគោរទេះហើយឲ្យពួកខ្ញុំធ្វើស្រែរួមទៀត ស្រែរួមហ្នឹងរបស់ខ្ញុំ៩០ហាត់ ហើយឲ្យពួកខ្ញុំហ្នឹងភ្ជួរស្រែគេ ហើយគេមិនអរហ្នឹងពួកខ្ញុំទេ ហើយលោកសុខ គង់ក៏អន់ចិត្តនិងពួកខ្ញុំដែរ កាលនោះជាការគ្រប់គ្រងរបស់ ខ្ញុំមិននៅក្នុងមន្ទីរ៥៧ដល់ពេលអញ្ចឹងកាលដែលបានអីៗមកប្រើពួកខ្ញុំពួកខ្ញុំធ្វើប៉ុន្តែមិនមែនធ្វើយកបុគ្គលទេគឺធ្វើរួមៗ

វណ្ណៈ៖ បាទ!

សាគៈ វាអញ្ចឹងមែនអត់មានប្រកែកបានទេ ដោយមានភស្តុតាងត្រឹមត្រូវ ។

វណ្ណៈ អញ្ចឹងតាសុខ គង់គាត់អន់ចិត្តដែរដោយសារយើងមកនៅទឹកដីគេហើយយើងប្រមូលផល ប្រជាជនគេទៀត?

សាគៈ យករបស់គេមកធ្វើអញ្ចឹង ទោះបីមិនមែនរបស់គាត់តែជាកូនទាហានរបស់គាត់ យកមកដកលិច គោលលោកប្អូនអើយលែងលិចក្បាលបាត់ហើយ ដល់ពេលអញ្ចឹងសកម្មប្រយុទ្ធវាមានដែរ ។

វណ្ណៈ អញ្ចឹងប្រជាជនអត់មានបះបោលទេ?

សាគៈ អត់ហ៊ានទេ ។

វណ្ណៈ អត់ហ៊ានទេ?

សាគៈ ហ្នឹងអើយ តែនៅក្នុងចិត្តគេមាន ដឹងតែមានហើយតែគ្រាន់តែវាអត់មានសកម្មភាព ។

វណ្ណៈ អញ្ចឹង?

សាគៈ បាទ! ពិតហើយ ។

វណ្ណៈ អញ្ចឹងដល់ពេលគាត់ស្លាប់ទៅដែលគេសម្លាប់អញ្ចឹង តើប្រហែលជាប្រជាជនមួយចំនួនគេ សប្បាយចិត្តឬគេយ៉ាងម៉េចដែរ?

សាគៈ ភាគច្រើនគេសប្បាយចិត្ត ហើយភាគតិចក៏មានការទ្រាំទ្រការរស់នៅរបស់គាត់ដែរ ហើយក៏ មើលឃើញពីការល្អខ្លះអញ្ចឹងណាលោកប្អូន វាមានពីរមានអ្នកគាំទ្រ មានអ្នកអរព្រោះ អរគេ ស្អប់ព្រោះដកទ្រព្យរបស់គេយកនោះ យកមកធ្វើជារបស់ខ្លួនឯងហើយនឹងធ្វើជារបស់រួម ។

វណ្ណៈ ដូចកាលជំនាន់ខ្មែរក្រហម?

សាគៈ បាទ! ដូចកាលជំនាន់ខ្មែរក្រហមដែរ ដូចខ្ញុំថាប្អូនដូចម៉ាដឹបអញ្ចឹងណា ពួកខ្ញុំទៅសុំរិភាគទាន អាសុំហ្នឹងហើយយ៉ាប់ជាងពន្ធដារនោះ ពន្ធដារវាមានឆ្នាំមានខែ ដល់អាទៅសុំចុះអត់ទេលោក ប្អូន បងប្អូនអើយសុំរិភាគទាន លោកប្អូនមានខ្ញុំទៅហើយ ព្រោះខ្លាចមិនឲ្យ អានេះលើសអា នេះជាការគិតរបស់ខ្ញុំណាលោកប្អូន វាពិតប្រាកដណាស់មិនថាម៉ែគេមិនថាម៉ែខ្ញុំទេឲ្យហើយ ឲ្យតែផុតៗចុះព្រោះមនុស្សជួបទាហានវៀតណាមនៅភូមិហ្នឹងផាប់ទៀតហើយ ដល់ពេលអញ្ចឹងឲ្យវា ចេញផុតទៅ ។

វណ្ណៈ អញ្ចឹងពូធ្វើទាហានរហូតដល់សមារណកម្មឬក៏ឈប់មុនហ្នឹង?

សាគៈ ខ្ញុំទើបតែឈប់នៅឆ្នាំ២០០៨នេះទេ ។

វណ្ណៈ អញ្ចឹង?

សាគៈ រដ្ឋឲ្យសធុននិវត្តន៍ព្រោះគ្រប់អាយុ ។

វណ្ណៈ  អញ្ចឹងពូបានប្រាក់និវត្តន៍សង្គមកិច្ច?

សាតៈ  សង្គមកិច្ចតែអត់គ្រប់ទេលោកប្អូន ដូចថាត្រូវ២០ម៉ឺនអញ្ចឹងបានតែ១៨,១៩ទេ ជួនកាល១៧ អញ្ចឹងទៅ ឧទាហរណ៍ថាមានប័ណ្ណពីនោះមក ដូចថាមានកូនសៀវភៅពីនោះមកវាច្បាស់អញ្ចឹង អត់បានទេ ដល់ពេលអញ្ចឹងវាបាត់រហូតរាល់ខែ មិនបាច់ថាអីទេពីត្រឹមកពេលផ្តល់ឲ្យហ្នឹងពី នាយករដ្ឋមន្ត្រីដែលថាកាន់អាហារហ្នឹងរំសាយទៅកន្លែងកោះកានោះ ឥលូវទៅ២៨ខែឲ្យត្រឹមតែ ១២ខែទេលោកប្អូនខ្ញុំលាក់លោកប្អូនទេ ខ្ញុំបានម៉ូតូក្រហមហ្នឹងមួយបានមួយពាន់បានបួនលាន នោះណាស់ ដូរទៅបានម៉ូតូហ្នឹងមួយខ្ញុំអត់លាក់ទេ ជីវិតគ្រួសារខ្ញុំបានអាក្នុងផ្ទះមួយហ្នឹង អាកូនដេកនោះ ហើយកញ្ចាស់អែហ្នឹងខ្ញុំអត់លាក់ទេ ហើយខ្ញុំអត់យកមកធ្វើផលទេលោកប្អូន ថាម៉ា បំណាច់ខ្ញុំតស៊ូឲ្យបានជិះមួយ ប្អូនមើលទៅកង់កញ្ចាស់មួយលោកប្អូនឃើញហើយទើបតែបាន ប្រហែលជាកន្លះខែហ្នឹងទេ ហើយអត់ឲ្យខ្ញុំគ្រប់របបទៀត ខ្ញុំត្រូវពីរឆ្នាំឲ្យខ្ញុំតែ១៨ខែទេ វាត្រូវ របស់ខ្ញុំ១៣២០០០០ទៀត។

វណ្ណៈ  អាហ្នឹងដូចវាមានបញ្ហាអញ្ចឹងមែនខ្លះៗហើយ ដោយសារយើងមិនទាន់បានពង្រឹងបញ្ហាពុករលួយអញ្ចឹង ដល់ពេលហើយគេកាត់យករបស់យើងខ្លះអញ្ចឹងទៅ។

សាតៈ  ហ្នឹងហើយដូចខ្ញុំជម្រាបលោកប្អូនអញ្ចឹងណា មើលឃើញទាំងអស់ អញ្ចឹងបានរាជរដ្ឋាភិបាល គាត់មិនចង់អញ្ចឹងទេគាត់ចង់ល្អ ចង់ឲ្យដឹកនាំទៅ ចង់ឲ្យការគ្រប់គ្រងរបស់គាត់ឲ្យស្អាតតាំងពី ក្រោមរហូតដល់លើណ៎បានស្អាត នេះមិនបន្ទោសគាត់ទេ សម្ភាសន៍នេះសម្ភាសន៍ដោយយុត្តិធម៌ហើយមិនកាន់ខាងណាៗទេ។

វណ្ណៈ  មែនហើយ យើងនិយាយថាយើងមើលឃើញល្អយើងថាល្អ បើថាគេល្អយើងនិយាយពី អាក្រក់អត់កើតទេ ព្រោះខ្ញុំធ្វើនេះខ្ញុំគ្រាន់តែចង់ដឹងថាអ្វីដែលល្អហើយអ្វីដែលអាក្រក់។

សាតៈ  បាទ!

វណ្ណៈ  បើជំនាន់ដែលនៅក្នុងសម័យខ្មែរក្រហមមានបងប្អូនខ្លះជាយោធាជាកម្មករនៅក្នុងភ្នំពេញគាត់អត់ ដែលខ្វះខាតទេ អញ្ចឹងរឿងរបស់គាត់គឺរឿងពិត គាត់អត់ខ្វះខាតមែនតែប្រជាជននៅក្រោយ គេកាប់សម្លាប់គាត់អត់ដឹងទេ។

សាតៈ  អត់ដឹងទេ។

វណ្ណៈ  គាត់ដឹងដែរ?

សាតៈ  ដឹងដែរតែគាត់មិនហ៊ាននិយាយ ដូចថាខ្ញុំនិយាយប្រាប់ប្អូនឯងហើយប្អូនឯងនិយាយប្រាប់គេ ទៀតគឺចប់ហើយ។

វណ្ណៈ បាទ!

សាគៈ ចប់ហើយគឺអត់មានរឿងអីទេ អត់មានអីទេប្អូនគឺត្បូងចបហើយនិងខ្មែរអង្រឹងហើយ អត់មានរយៈទៅ ចុះបើយើងអត់មានហ៊ានរត់ទៅជាមួយបងប្អូនវៀតណាម មនុស្សយើងវាខាសគ្នាហើយ បើខ្ញុំដឹងពីជំនាន់នោះថា បើសិនជាខ្ញុំទៅហើយខ្ញុំឆ្លងទៅដល់បងប្អូនវៀតណាមបាញ់នៅសុខទេគឺអត់សុខទេ ម៉ាម៉ឺនម៉ាដោះគឺអត់រួតទេ ហើយអត់មានអាងអីទេគឺទៅ ខ្ញុំធ្វើឲ្យទៅលើម៉ឺនហ្នឹង ។ ។

វណ្ណៈ បាទ! អញ្ចឹងកាលហ្នឹងពូមានរត់ទៅជុំរុំទេ?

សាគៈ អត់ដែលបានស្គាល់ជុំរុំគេមួយថ្ងៃឬក៏មួយនាទីទេ បើឧទាហរណ៍អញ្ចេះដូចជុំរុំអូរត្រាវអញ្ចឹងណា៎ ដើរកាត់ឆ្លងកាត់ទៅធ្វើការសុទ្ធតែខម្មាក់គ្រាប់ ហើយឆ្លងកាត់ជុំរុំមកនៅជុំរុំហ្នឹងហើយពឹងពាក់សុំអង្ករ សុំត្រីខទៅ ហើយធ្វើការប្រចាំដែលធ្វើហៅថាធ្វើការខ្លួនឯងនោះណា៎ ។

វណ្ណៈ បាទ!

សាគៈ ជូនរដ្ឋ ។

វណ្ណៈ ដល់ពេលអញ្ចឹងទៅក៏គ្មានឱកាសចង់ចេញទៅក្រៅប្រទេសដូចជាប្រទេសអាមេរិក បារាំង ម៉ាឡេអីហ្នឹង?

សាគៈ ចង់ តែវាអត់មានស្នូរអត់មានខ្មែរ ដូចថាទៅថ្នាក់នេះដូរទៅថ្នាក់នោះបានណា៎ គឺដឹងច្បាស់អញ្ចឹងទៅណា៎ ។

វណ្ណៈ បាទ!

សាគៈ ទីមួយចង់ដឹងចង់ចេះថាស្រុកគេយ៉ាងម៉េច ចង់ដឹងភាសានោះ ចង់បានទូរចំនេះដឹងមិនចង់មានបានអីទេ ចង់ឲ្យមានសេរីភាពជាមនុស្សមួយដែលគេហៅថាកុំនៅក្នុងអណ្តូងនោះណា៎ កង្កែបកុំធ្លាក់ក្នុងអណ្តូងនោះ ។

វណ្ណៈ បាទ! អញ្ចឹងដូចថានៅក្នុងពេលហ្នឹងពូមានធ្លាប់ឃើញប្រជាជន ប្រជាជនដែលរត់មកពីភ្នំពេញខាងក្នុងពីងឲ្យទាហានខ្មែរក្រហមជូនទៅថៃអីមានទេ?

សាគៈ អត់មានទេលោកប្អូន បើបងប្អូនពលរ៉ូ ។

វណ្ណៈ ពលរ៉ូហ្នឹងយ៉ាងម៉េចទៅ?

សាគៈ បងប្អូនពលរ៉ូចង់និយាយថា ពលរ៉អ្នកគស្ញ ។

វណ្ណៈ អាហ្នឹងឈ្មោះអីគេ?

សាគៈ ពលរ៉ូហ្នឹងយួនដូចគ្នា អាយួនមួយយួនតស៊ូដែលបងប្អូនវៀតណាមរាល់ថ្ងៃនេះណា មួយទៀតយួនតស៊ូផ្តាច់ការប៉ុល ពត មកពឹងពាក់ជាមួយចិនគេស៊ីជាមួយចិនណា៎ ហើយតស៊ូជាមួយបងប្អូនកាលហ្នឹងអត់ទាន់រត់ នៅលើជួរភ្នំក៏គេពឹងពាក់ដែរ ពឹងពាក់គ្នារហូត ។

វណ្ណៈ អញ្ចឹងមានខ្មែរយើងពឹងពាក់ថៃអីទេ?

សាគៈ មាន ។

វណ្ណៈ មានដែរ?

សាគៈ មាន ជួនកាលរត់ចេញពីកងទ័ពអញ្ចឹងទៅ ទៅតែទៅភាគតិច ភាគច្រើនគឺគេនៅលំនឹងពឹងពាក់ណា៎ គេអត់ទៅជឿខាងហ្នឹងទេ ពីព្រោះមានខ្មែរសេរីមានខ្មែរអ្នកតស៊ូ អ្នកតស៊ូគេដឹកនាំត្រឹមត្រូវ វាមានលំបាកមួយផ្នែក តែសេរីនោះវាមានតិចកើតមាន ។

វណ្ណៈ បាទ! អញ្ចឹងនៅកំរៀងយើងនេះដូចថាមីនអីមានដាក់តែខ្មែរក្រហមឬក៏មានខាងក្នុងដាក់ដែរ?

សាគៈ ខាងក្នុងក៏ដាក់ ខាងពួកខ្ញុំក៏ដាក់តែដាក់ការពារដីដូចដែលខ្ញុំបាននិយាយប្រាប់លោកប្អូនអញ្ចឹងណា៎ បើមិនដាក់មានដីពីណានៅ ដូចខ្ញុំនិយាយមេញថាបងក៏ដោយប្អូនក៏ដោយតែមើលអត់ទាន់បាញ់ងាប់ហើយ ដូចស្រុកខ្ញុំនៅទល់គ្នានៅកំរៀងហ្នឹងតើ ប្អូនដីដូនមួយហ្នឹង អត់ដឹងថាបងប្អូនឯង ។

វណ្ណៈ ចុះប្រជាជននៅនេះចូលមកដីបូងកាប់ព្រៃកាប់អីធ្វើចំការ ហើយមានប៉ុន្មានគ្រួសារទៅ?

សាគៈ មាន៦គ្រួសារ មានគ្រួសារយាយឡៃណា៎ ហើយមានពីរគ្រួសារទៀតគឺបងឆយនៅខាងមាត់អូរគ្រួសារហ្នឹងទេដែលស្នាក់នៅនេះណា ក្រៅពីហ្នឹងប្រយ័ត្នទៅ ។

វណ្ណៈ បាទ!

សាគៈ ដុតរួចរាវហើយបានហ៊ានចូលណាលោកប្អូន ។

វណ្ណៈ បាទ!

សាគៈ នៅមានគ្រោះថ្នាក់បន្ត ។

វណ្ណៈ អាហ្នឹងដោយសារយើងកាប់វាលដីណោះ?

សាគៈ បាទ! គេដាក់អញ្ចេះកាប់ប្រវែងនេះកន្លះម៉ែត្រ ហើយឲ្យទុកប្រវែងនេះទេពីដីណា៎ ដល់ពេលអញ្ចឹងយើងថាឈើគេកាប់ហើយអត់អីទេ ដល់ពេលភ្ជួរដីហើយវាផ្ទុះនៅហ្នឹង ដាក់ជ្រៅ ។

វណ្ណៈ ចុះពូបើតាមពូដឹងពូមករស់នៅតំបន់ហ្នឹងដូចថាព្រៃឈើអីចាប់ផ្តើមរីករិល ឬក៏អស់ពីបន្ទាយអីនៅឆ្នាំណាពិតប្រាកដទៅ?

សាគៈ បន្ទាយឈើចាប់តាំងពីកកើតទាំងឈើតូចទាំងឈើធំ មិនថាធំប៉ុនពាងអីទេ បងប្អូនអ្នកខ្វះខាត ហើយយកទៅដោះដូរដូចឧទាហរណ៍ថាមិនបាច់និយាយឲ្យវែងឆ្ងាយទេ បានឈើប៉ុនៗហ្នឹងទម្រាំបានឈើដាក់ផ្ទះហ្នឹងគ្នាអស់ពីចំការហើយ ក៏បានប៉ុណ្ណឹងដោយសារការខ្វះខាតក្រពះណាលោកប្អូន

វណ្ណៈ: បាទ!

សាគៈ ដោះដូរស៊ីរហូត លោកប្អូនឯងមើលបានឈើទៅលក់ទិញប្រេង ទិញប្រេងហើយដូលអាត្រាក់ភ្ជួរ ទិញពូជទិញថ្នាំ ដល់ពេលអញ្ចឹងទម្រាំបានឃើញប៉ុណ្ណឹងដូចអស់ពីដួងចិត្តហើយ ហើយកាយដីបន្ទូរទាំងញើស បូជាគ្រប់ផ្នែកតែម្តងទាំងញើសទាំងឈាម ។

វណ្ណៈ: ចុះនៅស្រុកហ្នឹងដំណាំដែលគេដាំជាប្រចាំហ្នឹងភាគច្រើនគេដាំដំណាំអីគេ?

សាគៈ ខ្លាំងជាងគេមានតែពីរទេ នៅស្រុកខ្ញុំហ្នឹងមានតែដំឡូងហើយនឹងពោត តែភាគច្រើនជាពោតឆ្នាំនេះ ។

វណ្ណៈ: បាទ!

សាគៈ ហើយទីពាកសិកម្មមួយទៀតដាំល្ងណាលោកប្អូន ល្ងបានដែរតែវាតូច ។

វណ្ណៈ: ពូដូចថាពូធ្លាប់បានឆ្លងកាត់ច្រើនជំនាន់អញ្ចឹង ដូចថាកាលពីសម័យតស៊ូហើយមកដល់បច្ចុប្បន្នវាមានលក្ខណៈខុសគ្នាយ៉ាងម៉េចដែរ?

សាគៈ ខុសច្រើនលោកប្អូន ទីមួយមានការដឹកនាំរបស់លោកនាយករដ្ឋមន្ត្រីមិនមានឈ្មោះមានចាញ់ដោយនាយករដ្ឋមន្ត្រីលោកហ៊ុន សែនមានការដឹកនាំគ្រប់លំដាប់ថ្នាក់ណា គាត់មានការរីកចម្រើន ទីមួយសំខាន់ជាងគេដើរតួផ្លូវ ទីពីរផ្តល់នូវភាពសុខសាន្ត ទីបីការរស់នៅមានសិទ្ធសេរីភាពមានការយល់ដឹងពីមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ពីអ្នកវិនិយោគទុនមក ទាំងក្រៅប្រទេសទាំងក្នុងប្រទេស ដូចជាលោកប្អូនអញ្ចឹងមកមានការយល់ដឹងអំពីរសម្ភាសន៍អញ្ចឹងមានច្រើនផ្នែកមានការយល់ដឹងគ្រប់ផ្នែកតែម្តង នាយករដ្ឋមន្ត្រីលោកដឹកនាំពេលនេះណា៎ មានការយល់ដឹងហើយឃើញឲ្យផ្ទាល់ភ្នែកគ្រប់កាលៈទេសៈ មានប្រដាប់ដោយជំនួយឲ្យបងប្អូនទោះបីមានតិចតួចក៏ដោយគាត់ផ្តល់ឲ្យគ្រប់គ្រួសារទោះបីមុនក្រោយក៏ដោយណា៎ អានេះការនឹកគុណដោយដឹងគុណចំពោះគ្រួសារយើងខ្ញុំហើយនឹងគ្រួសារអ្នកដទៃ វាមិនបានគ្រប់គ្នាគ្រាន់ថាមុនហើយនឹងក្រោយហើយក៏មានមេភូមិមេក្រុមគេមក វាមានលំដាប់ថ្នាក់គេអញ្ចឹងណាលោកប្អូន ។

វណ្ណៈ: ចុះអ្នកស្រុកហ្នឹងតាមធម្មតាដូចថាមានដីស្រែចំការអញ្ចឹង ហើយមានពេលទំនេរឬក៏ទៅស៊ីឈ្នួលគេនៅស្រុកថៃដែរឬក៏មិនមានទេ?

សាគៈ ចំពោះនៅកន្លែងនេះអត់មាមអ្នកចូលទេ មានតែបងប្អូនដូចថាតាកែវ ពីកំពង់ធំអញ្ចឹងមក វាមានដែរគ្រាន់ថាវាតិច ដូចថា១០០ផ្ទះ ២០០ផ្ទះវាមានមួយមានពីរទេ អត់ចូលទេដូចម្ដុំខ្ញុំនេះមានអ្នកទៅចាប់សត្វបើថារឿងទៅស៊ីឈ្នួលធ្វើកម្មករអីវាមានច្រើនណាលោកប្អូន ។

វណ្ណៈ បាទ!

សាគៈ យើងមើលឃើញថាថៃវាមិនមែនឲ្យយើងស្រួលទេណាលោកប្អូន មិនស្រួលត្រង់ថាយើងឃើញស្រាប់ហើយគេចាំតែយក គេអប់រំកូនគេទឹកដីគេនៅបាត់ដំបងនោះ សៀមរាបនោះ ហើយយើងឃើញច្បាស់ថាទឹកដីយើងនៅហ្នឹងហើយ ហើយព្រះគោព្រះកែវអីច្បាស់ណាស់ យើងនៅហ្នឹងទាំងអស់ ។

វណ្ណៈ យើងដូចថាឥឡូវមិនបាច់ទាមទារដល់ខ្មែរទេ ឲ្យតែការពារអ្វីដែលមានសព្វថ្ងៃនេះឲ្យតែបានល្អទៅវាល្អម្យ៉ាងដែរ ។

សាគៈ ចំពោះខ្ញុំនេះហើយនឹងចំពោះថៃខ្ញុំទៅស្ដាប់មួយម៉ោងក៏ខ្ញុំធ្វើបានដែរ ឲ្យតែរាជរដ្ឋាភិបាលសម្រេចថាវៃ ខ្ញុំសុំតែ៣០០នាក់ទេ ៣០០នាក់គុណនឹង៥០ចុះ មានតែប៉ុណ្ណឹងទេលោកប្អូនចេញមកវិញដូចសំបុកមាន់ ធម្មតាសង្គ្រាមវិនាសសកម្ម វាហិនហោចហើយ អានេះយល់ដឹងទាំងអស់គ្នា បើសង្គ្រាមរីកចម្រើនអ្នកណាក៏ចង់ធ្វើដែរ ហើយវាហិនហោចបានលោកនាយករដ្ឋមន្ត្រីគាត់មិនចង់ឲ្យកើតនេះ ហើយលោកចង់ណាស់សុខសាន្ត អ្នកដែលឆ្លងកាត់ពីប្រទេសមួយទៅប្រទេសមួយទៀតគាត់ខំណាស់ ។

វណ្ណៈ ឆ្លងកាត់សង្គ្រាម?

សាគៈ បាទ!

វណ្ណៈ អញ្ចឹងទាក់ទងនឹងការរកស៊ីនៅស្រុកភូមិនេះតើពូសង្កេតឃើញប្រជាជនមានជីវភាពល្អមធ្យមឬក៏មានជីវភាពខ្វះខាតដែរ?

សាគៈ សព្វថ្ងៃខ្ញុំនិយាយឲ្យត្រង់ចុះភាគគ្នាអត់ អ្នកដែលគេបានបងប្អូនគឺគេបានហើយមានអាត្រាក់មួយទៅអាត្រាក់ពីរ នេះខ្ញុំនិយាយនេះមិនមែននិយាយបងប្អូនអ្នកបានទេណ៎ បងប្អូនអ្នកបានគឺបានហើយ ហើយបងប្អូនអ្នកគឺអត់តែម្ដង ខ្ញុំនិយាយនេះគឺមិនមែនថាស្អប់ខ្មែរយើងដូចគ្នានោះទេ អរណាស់អ្នកដែលបានព្រោះស្រណុករកគេដោយស្មោះអស់ពីដួងចិត្ត ។

វណ្ណៈ អញ្ចឹងដូចថាយើងយកដីហ្នឹង ហើយយើងធ្វើទៅវាប៉ះពាល់?

សាគៈ ដីវាអត់ត្រូវរឿង ដូចខ្ញុំនេះមិនអត់ទេដី ប៉ុន្តែដីនេះធ្វើក្នុងមួយហាត់បានតែមួយរ៉ៃទេលោកប្អូន ។

វណ្ណៈ បាទ!

សាតៈ ផលបានតែមួយរ៉ៃ ហើយយកទៅប្រៀបគេម៉េចកើត ។

វណ្ណៈ បាទ!

សាតៈ ហើយខ្ញុំអត់ភទេ ដឹកដៃទៅមើលដីក៏បាន អត់មានភអួនឯងទេ នៅនោះមាត់អូរ ហើយមួយភូមិនេះអ្នកណាក៏ដឹងថាដីខ្ញុំហើយនឹងដីយាយហ្នឹងជាប់គ្នាដែរ មិនមែនថាមិនធ្វើទេអាហ្នឹងហើយដែលថាយកលុយគេត្រូតណាលោកប្អូន ។

វណ្ណៈ បាទ!

សាតៈ អញ្ចឹងខ្ញុំចង់សួរបន្តិចទៀតថាប្រជាជនភូមិនេះសព្វថ្ងៃនៅច្រើនទេពូ?

វណ្ណៈ ច្រើន ។

សាតៈ ច្រើន?

វណ្ណៈ ច្រើនរយគ្រួសារដែរ?

សាតៈ ច្រើនរយគ្រួសារ គ្រាន់តែម៉ាភូមិខ្ញុំនេះមួយគ្រួសារបាត់ហើយ ម៉ាភូមិស្វាយជ្រៃនេះ លោកមេភូមិទទួលស្គាល់ដោយគ្មានបញ្ហារាយនាមជាប់ ។

វណ្ណៈ ចុះនៅហ្នឹងមានវត្តវ៉ាតាំងពីពេលណា?

សាតៈ មានវត្តវ៉ាតាំងពីកកើតភូមិ បង្កើតវត្តដោយស័ក្រូចិត្ត ។

វណ្ណៈ កើតវត្តមុនសមារណកម្មឬក្រោយ?

សាតៈ សមារណកម្ម ។

វណ្ណៈ សមារណកម្មមានវត្តតែម្តង?

សាតៈ សមារណកម្មតែម្តង ។

វណ្ណៈ មានវត្តមានសាលារៀនអី?

សាតៈ សាលារៀនមកបង្កើតរហូត ។

វណ្ណៈ មានវិទ្យាល័យទេ?

សាតៈ មាន ។

វណ្ណៈ អញ្ចឹងកាលហ្នឹងមានវិទ្យាល័យមានវត្តមានអីណោះ?

សាតៈ បាទ!

វណ្ណៈ អញ្ចឹងពូខ្ញុំចង់សួរពូបន្តិចទៀតថាដោយសារនៅក្នុងជំនាន់៣ឆ្នាំធ្វើឲ្យជីវិតមនុស្សស្លាប់ច្រើន ធ្វើការហួសកម្លាំង អត់អាហារអត់អីអញ្ចឹងដល់ពេលឥលូវគេតម្រូវឲ្យមានតុលាការជាតិចូលជា

មួយតុលាការយើងសព្វថ្ងៃនេះ ហើយមានការកាត់ទោសមេដឹកនាំកំពូល៦នាក់ដាប់ឃុំហ្នឹងតើពូគិតថាជាការត្រឹមត្រូវឬក៏មិនត្រឹមត្រូវទេធ្វើហ្នឹង?

សាគៈ បើតាមខ្ញុំវិភាគមើលទៅតុលាការហ្នឹងកើតមានឡើងគ្នាយើងគេបានដឹងគ្រប់គ្នាហើយណា៎ ដល់ពេលអញ្ចឹងការកាត់ទោសហ្នឹងម្យ៉ាងសមស្របទៅតាមសភាពការណ៍ ។

វណ្ណៈ បាទ!

សាគៈ ការដឹកនាំដូចខ្ញុំតែងនិយាយពីមុនមកហើយបច្ចុប្បន្ននេះវាមានខុសនឹងត្រូវណាលោកប្អូន ដល់ពេលអញ្ចឹងទៅតាមសភាពការណ៍ដែលលោកមានការឈ្លាសវៃ នេះតាមយោបល់របស់ខ្ញុំ ខ្ញុំអត់មានទៅបន្ទោសអ្នកណាទេ អត់មានថាខាងណាល្អខាងណាអាក្រក់ទេណា៎ ព្រោះមានតែនាយករដ្ឋមន្ត្រីទេដែលគាត់ឈ្លាសវៃដឹកនាំសព្វថ្ងៃនេះ ។

វណ្ណៈ បាទ!

សាគៈ មានគាត់ដើម្បីឈ្នះ ហើយមានដីឲ្យប្រជាពលរដ្ឋនៅ មានស្រុកមានភូមិ នឹងមានសាលារៀនកូនដើរ ។

វណ្ណៈ ប៉ុន្តែខ្ញុំចង់សួរពូខ្លីដូចថា ពូថាមានតុលាការកាត់ទោសហ្នឹងជាការត្រឹមត្រូវហើយមានប្រយោជន៍យ៉ាងម៉េចដែរ?

សាគៈ មានប្រយោជន៍ដល់ប្រជាជន ដល់ពេលបានជំនួយមកគាត់ចែកប្រជាជនហូប ដូចនេះខ្ញុំថាវាត្រឹមត្រូវតាមការដឹកនាំកាលៈទេសៈអ្នកដឹកនាំ ។

វណ្ណៈ អញ្ចឹងពូគិតថាការកាត់មេដឹកនាំទាំងប៉ុន្មានហ្នឹងវាត្រឹមត្រូវហើយ?

សាគៈ បាទ! ត្រឹមត្រូវហើយព្រោះទៅតាមការជាក់ស្តែងនិងការប្រព្រឹត្ត ។

វណ្ណៈ អញ្ចឹងខ្ញុំដូចជាអស់មានសំនួរសួរពូទៀតហើយ ខ្ញុំសូមអរគុណពូច្រើន ។

សាគៈ បាទ!